

ការចាប់ផ្តើមថ្ងៃថ្មី



(14)

នេះគឺជាពាក្យរបស់លោក ដេវក ព្រីនស៍
ដែលបានដកស្រង់ពីព្រះបន្ទូលនៃព្រះសម្រាប់លោកអ្នក។

> «ឱព្រះយេហូវ៉ាអើយ នៅពេលព្រឹក
> ទ្រង់នឹងឮសម្តែងរបស់ទូលបង្គំ គឺនៅពេលព្រឹក
> ទូលបង្គំនឹងទូលដល់ទ្រង់ ដោយលំដាប់
> ព្រមទាំងរក្សាពេលចាំយាមផង»។ [ទំនុកតម្កើង ៥:៣]

តើអ្នកចាប់ផ្តើមថ្ងៃថ្មីនីមួយៗយ៉ាងដូចម្តេច?
តើថ្ងៃរបស់អ្នកចាប់ផ្តើមដោយការឥតមានលំដាប់លំដោយ
ដោយការច្របូកច្របល់ ដោយការព្យាយាមធ្វើរឿងបីខុសគ្នា
ក្នុងពេលតែមួយឬទេ?
តើអ្នកបានឃើញថាខ្លួនឯងជាញឹកញាប់មានដង្ហើមខ្លី ឆាប់ខឹង
ឬខឹងនឹងភរិយា ឬបតីរបស់អ្នក ស្តីបន្ទោសកូនៗ មិនសប្បាយចិត្ត
មានអារម្មណ៍ព្រួយបារម្ភ និងមានការភាន់ភាំងឬទេ?

តើអ្នកបានចាប់ផ្តើមថ្ងៃថ្មីរបស់អ្នកដោយមិនបានត្រៀមខ្លួនរៀបចំទុក
ជាមុន ឬមិនបានប្រដាប់ដោយអាវុធ
មិនមានទំនុកចិត្តនូវអ្វីដែលនឹងកើតឡើងចំពោះអ្នកនៅពេលខាងមុខ
នោះទេ?
មូលហេតុគឺអ្នកមិនបានចាប់ផ្តើមថ្ងៃថ្មីរបស់អ្នកឲ្យបានត្រឹមត្រូវ។
ចូរទទួលយកមេរៀនមួយពីស្តេចដាវីឌ។
ទ្រង់មានបន្ទូលទៅកាន់ព្រះអម្ចាស់ថា៖ «ព្រះយេហូវ៉ាអើយ
នៅពេលព្រឹក ទ្រង់នឹងឮសម្តែងរបស់ទូលបង្គំ»។

ការដំបូងដែលដាវីឌបានធ្វើរាល់ព្រឹកគឺបន្លឺសម្តែងទៅព្រះអម្ចាស់។
គាត់និយាយបន្តថា៖ «គឺនៅពេលព្រឹក ទូលបង្គំនឹងទូលដល់ទ្រង់
ដោយលំដាប់ ព្រមទាំងរក្សាពេលចាំយាមផង
(រង់ចាំដោយមានសេចក្តីសង្ឃឹមទុក)»។
នេះគឺជាវិធីប្រកបដោយប្រាជ្ញាក្នុងការចាប់ផ្តើមថ្ងៃថ្មី។

ចូរបន្លឺសម្តែងរបស់អ្នកទៅកាន់ព្រះអម្ចាស់តាមរយៈការអធិស្ឋាន។
ចូរទូលថ្វាយនូវសំណូមពររបស់អ្នកនៅចំពោះទ្រង់។
ចូរថ្វាយផែនការរបស់អ្នកទៅព្រះអម្ចាស់
នូវអ្វីដែលអ្នកនឹងត្រូវធ្វើនៅថ្ងៃនោះ។ ចូរថ្វាយដល់ទ្រង់អំពីបញ្ហា
ការលំបាកដែលអ្នកបានគិតទុកជាមុន
ហើយបន្ទាប់មកដូចជាស្តេចដាវីឌដែរ
អ្នកនឹងអាចរង់ចាំដោយមានសេចក្តីសង្ឃឹមទុក។

អ្នកនឹងមិនព្រួយបារម្ភឬមានការភ័យខ្លាចអ្វីឡើយ។
អ្នកនឹងរង់ចាំទទួលចម្លើយចំពោះការអធិស្ឋានទាំងនោះ
ដែលអ្នកបានថ្វាយដល់ព្រះអម្ចាស់នៅពេលព្រឹក។
ចូរចាំថានេះគឺជាអាថិកំបាំង។
ចូរចាប់ផ្តើមថ្ងៃនីមួយៗរបស់អ្នកដោយអនុញ្ញាតឲ្យព្រះអម្ចាស់ឮសម្ដេ

ឯរបស់អ្នក។

: WD-WFTW-014-KHM
: 24 Feb 2026
: derekprince.com/km/resources

